ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំទី ១០ លេខ ១១

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ




Work Activities

ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧



# មាតិកា


| ល.រ បរិយាយ | លេខទំព័រ |
|---|---|
| I- កិច្ចប្រជុំជំនាញបច្ចេកទេស | |
| ១- សេចក្តីព្រាងច្បាប់ស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ | ១-២ |
| ២- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ | ៣ |
| II- កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែតុលា ឆ្នាំ២០១៧ | ៤-១២ |
| III- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ឃឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧ | ១៣-១៥ |

# ១- សេចក្តីព្រាងច្បាប់ស្តីពី

## ការការពាររុក្ខជាតិ និងភូតគាមអនាម័យ

រយៈពេល ០៩ ថ្ងៃ គឺចាប់ពីថ្ងៃទី១១ ខែតុលា ដល់ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **អ៊ុច ថោងសេង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **សុក ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងច្បាប់ស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ** ដោយមានការអញ្ជើញចូលរួមពី សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សេចក្តីព្រាងច្បាប់ស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ គឺជាសមិទ្ធិផលមួយទៀតក្នុងការអភិវឌ្ឍបទដ្ឋានគតិយុត្តរបស់វិស័យកសិកម្ម ក្នុងក្របខណ្ឌសុវត្ថិភាពស្បៀង បន្ទាប់ពីច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ក្នុងគោលដៅគាំទ្រគោលនយោបាយអភិវឌ្ឍវិស័យកសិកម្ម យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា និងគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។

ខែវិច្ឆិកាឆ្នាំ១៩៥១ អនុសញ្ញាអន្តរជាតិការពាររុក្ខជាតិត្រូវបានអនុម័តនៅក្នុងសម័យប្រជុំលើកទី៦ នៃសន្និសីទរបស់អង្គការស្បៀងនិងកសិកម្មសហប្រជាជាតិនាទីក្រុងរ៉ូម និងត្រូវបានចូលជាធរមាននៅថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៥២ ដែលមានសមាជិកភាគីសរុប ១៣៩ រដ្ឋ ហើយត្រូវបានចុះបញ្ជីលេខ១៩៦៣ តម្កល់ទុកនៅអង្គការសហប្រជាជាតិ នាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៥២។ ព្រះរាជាណាចក្រកម្ពុជា ត្រូវបានទទួលស្គាល់ជារដ្ឋភាគីភ្ជាប់កាតព្វកិច្ចជាមួយអនុសញ្ញានេះនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៥២ បន្ទាប់ពីអនុសញ្ញានេះត្រូវបានចូលជាធរមាន។ អនុសញ្ញាអន្តរជាតិការការពាររុក្ខជាតិ ត្រូវបានចាប់ផ្តើមធ្វើវិសោធនកម្មអត្ថបទនៃអនុសញ្ញាក្នុងសម័យប្រជុំលើកទី២០ នៃសន្និសីទរបស់អង្គការស្បៀងនិងកសិកម្មសហប្រជាជាតិទីក្រុងរ៉ូម នាខែវិច្ឆិកាឆ្នាំ១៩៧៩។

មកដល់ឆ្នាំ១៩៨៤ កម្ពុជាត្រូវបំពេញតួនាទីជារដ្ឋភាគីនៃអនុសញ្ញាអន្តរជាតិការការពាររុក្ខជាតិបន្តទៀត ដែលក្នុងដំណាក់កាលនោះ ការងារត្រួតពិនិត្យភូតគាមអនាម័យត្រូវបានចាប់ផ្តើមដំណើរការក្រោមវិសាលភាពនៃអនុក្រឹត្យលេខ៩៨ អនក្រ ឆ្នាំ១៩៨៣ ស្តីពីការត្រួតពិនិត្យភូតគាមអនាម័យលើផលិតផលរុក្ខជាតិនាំចេញ និងនាំចូល។ ចាប់ពីពេលនោះមក មន្ត្រីជំនាញភូតគាមអនាម័យ ត្រូវបានទទួលការបណ្តុះបណ្តាលពីមន្ត្រីជំនាញភូតគាមអនាម័យអនាម័យនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម និងអតីតសហភាពសូវៀត

តាមរយៈការរៀនផង អនុវត្តផ្ទាល់ផង ដែលកាលនោះ ការងារភូតគាមអនាម័យ បានផ្តោតការយកចិត្តទុកដាក់ជាខ្លាំងទៅលើការពិនិត្យផលិតផលកសិកម្ម ដែលជាជំនួយស្បៀងអាហារពីបរទេស ដើម្បីទប់ស្កាត់ការរាលដាលឆ្លងសមាសភាពចង្រៃពីប្រទេសជាម្ចាស់ជំនួយទាំងនោះ។ ភ្នាក់ងារភូតគាមអនាម័យជាច្រើនរូបត្រូវបានបណ្តុះបណ្តាល និងដំណើរការការងារភូតគាមអនាម័យនៅតាមទីស្នាក់ការច្រកទ្វារព្រំដែននានាទាំងផ្លូវគោក ទាំងផ្លូវទឹក កំពង់ផែអន្តរជាតិ និងព្រលានយន្តហោះពោធិចិនតុង។ ដោយមានយន្តការត្រួតពិនិត្យនេះ ទើបកម្ពុជាអាចទប់ស្កាត់បាននូវវត្តមានរបស់សត្វល្អិតចង្រៃបំផ្លាញផលិតផលក្នុងឃ្លាំងឈ្មោះ trogodema granarium ដែលនៅក្នុងទស្សវត្សទី៨០ មានការរាលដាលឆ្លង និងបំផ្លាញផលិតផលរុក្ខជាតិយ៉ាងខ្លាំងនៅទ្វីបអឺរ៉ុប និងអាស៊ី។

បន្ទាប់មក នាខែវិច្ឆិកា ឆ្នាំ១៩៩៧ សម័យប្រជុំលើកទី២៩ នៃសន្និសិទ របស់អង្គការស្បៀង និងកសិកម្ម(FAO) បានអនុម័តយល់ព្រមលើអត្ថបទវិសោធនកម្មអនុសញ្ញាទាំងស្រុង ដែលមានសមាជិកភាគីចំនួន ៩០ រដ្ឋ បានផ្តល់លិខិតុបករណ៍យល់ព្រម ក្នុងនោះព្រះរាជាណាចក្រកម្ពុជា ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាស្ថាប័នបង្គោលថ្នាក់ជាតិអនុវត្តអនុសញ្ញានេះ។

មកដល់ឆ្នាំ១៩៩៩ នៅពេលដែលព្រះរាជាណាចក្រកម្ពុជាក្លាយជាសមាជិកអាស៊ាន និងឆ្នាំ២០០៤ ជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក(WTO) ការងារភូតគាមអនាម័យត្រូវបានពង្រឹងឡើងវិញ ដើម្បីត្រួតពិនិត្យទំនិញដែលធ្វើពាណិជ្ជកម្មនៅពេលដែលរបាំងគយ ត្រូវកាត់បន្ថយរហូតដល់សូន្យ នៅតាមបណ្តាប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍នានាក្នុងសកលលោក ជាពិសេសប្រទេសជាសមាជិក WTO។ នៅដំណាក់កាលនោះរាជរដ្ឋាភិបាលបានសម្រេចចេញនូវអនុក្រឹត្យលេខ១៥ អនក្រ.បក ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាមអនាម័យ ដើម្បីជាឧបករណ៍គតិយុត្តិឆ្លើយតបតាមលក្ខខណ្ឌតម្រូវរបស់WTO។

ឆ្លងតាមការអនុវត្តជាក់ស្តែង អនុក្រឹត្យលេខ១៥ អនក្រ.បក ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាមអនាម័យ មានបទប្បញ្ញត្តិមិនទាន់គ្រប់គ្រាន់អំពីយន្តការគាំទ្រ នីតិវិធី និងដំណើរការបានសមស្របតាមលក្ខខណ្ឌតម្រូវរបស់អនុសញ្ញាអន្តរជាតិការពាររុក្ខជាតិ និងកិច្ចព្រមព្រៀងស្តីពីអនាម័យ និងភូតគាមអនាម័យនៅឡើយដែលធ្វើឲ្យយើងនៅជួបបញ្ហាជាច្រើនក្នុងការអនុវត្ត ក៏ដូចជានៅមិនទាន់បានឆ្លើយតបគោលការណ៍សមារណកម្មតំបន់និងសកលក្នុងលក្ខខណ្ឌការងារភូតគាមអនាម័យនៅឡើយ។ ដើម្បីបំពេញលក្ខខណ្ឌតម្រូវនៃសមាជិកភាព WTO និងបំពេញតួនាទីជាភាគីហត្ថលេខីនៃអនុសញ្ញាអន្តរជាតិការពាររុក្ខជាតិ ស្រមតាមស្ថានភាពរីកចម្រើនយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចជាតិចំពោះមុខ នោះអនុក្រឹត្យលេខ១៥ អនក្រ.បក ឆ្នាំ២០០៣ ចាំបាច់ត្រូវតែជំនួសដោយច្បាប់ស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ ដែលអាចអនុវត្តប្រកបដោយសង្គតិភាពជាមួយ បណ្តាប្រទេសក្នុងតំបន់ និងសកលលោក[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនាពេលខាងមុខ៕

---

[១] អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុរបស់សេចក្តីព្រាងច្បាប់ស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ។

## ២- សេចក្តីព្រាងអនុក្រឹត្យស្តីពី

### ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ

កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អួន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **សុក ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ ដោយមានការអញ្ជើញចូលរួមពី សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារនេះ ត្រូវបានតាក់តែងឡើងស្របតាមការចង្អុលបង្ហាញនៃបញ្ញត្តិមាត្រា៨ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ ដែលត្រូវបានប្រកាសឲ្យប្រើកាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦។ ការបង្កើតអគ្គលេខាការដ្ឋានេះនឹងក្លាយជាយន្តការសម្របសម្រួលដ៏មានសារៈសំខាន់ សម្រាប់គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារលើកិច្ចសហប្រតិបត្តិការ ការជំរុញអនុវត្តគោលនយោបាយ ការចងក្រងរបាយការណ៍ ការវាយតម្លៃស្ថានភាពពលកម្មកុមារ និងបញ្ហាថ្មីៗមួយចំនួនទៀតដែលត្រូវដោះស្រាយបន្ទាន់សម្រាប់ការលុបបំបាត់ពលកម្មកុមារនៅប្រទេសកម្ពុជា។

សេចក្តីព្រាងអនុក្រឹត្យនេះត្រូវបានបង្កើតឡើងក្នុងគោលបំណង ដើម្បីកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ ដែលហៅកាត់ថា អគ្គ-លេខាធិការដ្ឋាន គ.ជ.ព.។

សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ ត្រូវបានដឹកនាំរៀបចំសរសេរដោយបានឆ្លងកាត់កិច្ចប្រជុំកម្រិតបច្ចេកទេស របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាច្រើនលើក ហើយបានដាក់ជូនថ្នាក់ដឹកនាំក្រសួង ក៏ដូចជាគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ ប្រជុំពិនិត្យ សម្រេច មុននឹងដាក់ឆ្លងកិច្ចប្រជុំកម្រិតខ្ពស់ទៀត។

សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារមាន ៤ ជំពូក និង៩ មាត្រា[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ មុននឹងដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនាពេលខាងមុខ៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុរបស់សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ។



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ **ប្រចាំខែតុលា ឆ្នាំ២០១៧** នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែតុលា ឆ្នាំ២០១៧សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ថយចុះ០,២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២,១%ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ភោជនីយដ្ឋាន: | +៧,២% | ប្រេងសាំង: | +៧,៦% |
| ការដឹកជញ្ជូន: | +៣,៧% | ប្រេងម៉ាស៊ូត: | +៧,២% |
| សំលៀកបំពាក់ និងស្បែកជើង: | +២,៨% | ត្រីស្រស់: | +៤,១% |
| ម្ហូបអាហារ: | +១,៩% | សាច់គោ: | +២,៤% |
| គេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +១,៧% | សាច់មាន់: | +១,២% |
| សុខាភិបាល: | +១,៣% | សាច់ជ្រូក: | +០,៥% |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់: | +០,៣% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៥–២០១៧

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា[P] | ធ្នូ[P] | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៧ | ដូចគ្នាឆ្នាំមុន | ៤,៤% | ៤,០% | ៤,២% | ៣,២% | ២,៥% | ២,៣% | ២,៣% | ២,៦% | ២,៧% | ២,១% | ២,២% | ១,៧% | ២,៩% |
| | មុន | ០,៣% | ០,១% | ០,០% | ០,៤% | -០,២% | ០,១% | ០,៣% | ០,៤% | ០,៣% | -០,២% | ០,២% | -០,១% | |
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ៣,០% | ២,៩% | ៣,០% | ៣,៤% | ៣,៦% | ៣,៩% | ៣% |
| | មុន | -០,២% | ០,៤% | -០,២% | ១,៤% | ០,៥% | ០,២% | ០,៣% | ០,២% | ០,៣% | ០,៤% | ០ | ០,៤% | |
| ២០១៥ | ដូចគ្នាឆ្នាំមុន | ០,៤% | ១,៦% | ១,១% | ១,៣% | ១,០% | ០,៧% | ០,៨% | ០,៨% | ០,៩% | ១,៣% | ១,៩% | ២,៨% | ១,២% |
| | មុន | -០,៤% | ១,២% | ០,១% | ០,៧% | ០,១% | ០,២% | ០,៦% | ០,៣% | ០,២% | ០% | -០,២% | ០,២% | |

P: តួលេខខែ វិច្ឆិកា ធ្នូ និងឆ្នាំ២០១៧ ជាតួលេខព្យាករ (តាមវិធីសាស្រ្ត DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ គាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសគាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. បម្រែបម្រួល និងចលនាសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

បម្រែបម្រួលសន្ទស្សន៍ថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុន




សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់(គ្រាគោល ២០០៦)




តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | តុលា ២០១៧ | កញ្ញា ២០១៧ | តុលា២០១៦ | *ប្រភេទ* | តុលា ២០១៧ | កញ្ញា ២០១៧ | តុលា ២០១៦ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៣៧៛/១$ | ៤០៥៣៛/១$ | ៤០៥០៛/១$ | **បាត/ដុល្លារ** | ៣៣,២១បាត/១$ | ៣៣,៣៨បាត/១$ | ៣៥,០៤បាត/១$ |
| **៛/បាត** | ១២២៛/១បាត | ១២១៛/១បាត | ១១៦៛/១បាត | **ដុង/ដុល្លារ** | ២២៧០២ដុង១$ | ២២៦៩៧ដុង១$ | ២២៣០៥ដុង/១$ |
| **៛/ដុង** | ០,១៧៨៛/១ដុង | ០,១៧៩៛/១ដុង | ០,១៨២៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់ធនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែតុលា ឆ្នាំ២០១៧ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១៣៨៦,៣ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ៣៤៦,៥លានដុល្លារ (*មធ្យមប្រចាំខែ១០៤% នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន១៣៨៦,៣ ប៊ីលានរៀល(*មធ្យមប្រចាំខែ ១០៤%នៃផែនការ*) និងគ្មានចំណូលមូលធនទេ(តាមតួលេខធនាគារជាតិ)។

➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិកើនឡើង១៩% និងកើនឡើង៤៤,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៥-២០១៧ (ប៊ីលានរៀល)




➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១១១៨ប៊ីលានរៀល កើនឡើង១០,៥% ធៀបនឹងខែមុន និងកើនឡើង៤០,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខ ធនាគារជាតិ)។

✓ចំណូលមិនមែនសារពើពន្ធមានចំនួន២៦៨,៣ប៊ីលានរៀល កើនឡើង៧៤,៧% ធៀបនឹងខែមុន និង កើនឡើង៧៦,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ ធនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងរង្វង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (តាមតួលេខ រតនាគារជាតិ) (ក្នុងរង្វង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: +៩,៦% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+៣៥%) | ➢កាស៊ីណូ : កើនយ៉ាងគំហុក | (+១៨៦,៤%) |
| | | ➢អាជ្ញាបណ្ណក្នុងស្រុក : +៣៤៤,១% | (+៨៣៣,១%) |
| ➢ ចំណូលពន្ធដារ: -១០,៤% (អគ្គនាយកដ្ឋានពន្ធដារ) | (+២០,២%) | ➢ នេសាទ: -៧៧,៤% | (-៩៣,៣%) |
| | | ➢សម្បទានរ៉ែ: +៥៨,៨% | (-៧,១%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: -១៦,៨% | (+១២,១%) |
| | | ➢អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ): +៥៨,៣% | (+៤៩,១%) |
| | | ➢ការត្រួតពិនិត្យគុណភាពផលិតផល: +២២០,៧% | (-៤៨,៤%) |

**២.២. ចំណាយថវិកាជាតិ** : អនុវត្តបាន ១៦៤០,៤ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ៤១០លានដុល្លារ( *មធ្យមប្រចាំខែ ៨៥% នៃផែនការ*) ក្នុងនោះ: ចំណាយចរន្តចំនួន ១៤៧៤ប៊ីលានរៀល ( *មធ្យមប្រចាំខែ ៩០% នៃផែនការ*) និងចំណាយមូលធនមានចំនួន ១៦៦,៥ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិកើនឡើង៤៥,៣% ធៀបនឹងខែមុននិងកើនឡើង៣៧,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង៧៦,១% ធៀបនឹងខែមុននិងកើនឡើង៤៥,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៥–២០១៧




**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានឱនភាពចំនួន ២៥៤,១ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ៦៣,៥លានដុល្លារ (តួលេខរតនាគារជាតិ)។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែតុលា ឆ្នាំ២០១៧មានលក្ខណ:ដូចខាងក្រោម:

➢រូបិយវត្ថុ$M_2$ មានចំនួន ៧០២៥៨ប៊ីលានរៀលកើនឡើង០,៧%ធៀបនឹងខែមុន និងកើនឡើង២២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង$M_2$** ក្នុងខែនេះ ជារួម បណ្តាលមកពីការកើនឡើងនៃ ប្រាក់បញ្ញើចរន្ត ១៤,៣% ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ ៣,២% និងប្រាក់បញ្ញើជារូបិយបណ្ណ០,៦%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែតុលា ឆ្នាំ២០១៧




➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៦,៦% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៣,៤% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៧

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៦,៧% | ១៦,៦% | ១៥,៥% | ១៥,៣% | ១៥,៧% | ១៦,០% | ១៦,៣% | ១៦,៦% | ១៦,៥% | ១៦,៦% | | |
| ប្រាក់រៀលក្រៅធនាគារ | ១១,៣% | ១១,៤% | ១១,៣% | ១១,៣% | ១១,២% | ១១,១% | ១១,៤% | ១១,៦% | ១១,៥% | ១១,៣% | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែកញ្ញា២០១៧: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន៨៤១៥លានដុល្លារ កើនឡើង០,៧%ធៀបនឹងខែមុន និងកើនឡើង២៦,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** : ក្នុងខែនេះមានចំនួន២៥៨៨៣ប៊ីលានរៀលកើនឡើង៤,៤%ធៀបនឹងខែមុន និងកើនឡើង៣១,២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *តុលា២០១៧* | *កញ្ញា២០១៧* | *តុលា២០១៦* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល) | ៦៥៦៧៥ | ៦៤៩៦១ | ៥៥៩៦៣ |
| ក្នុងនោះ ជារៀល | | ១១៥៧ | ៨១៣ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | ១៦១៦៣ | ១២០៤១ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៩៧% | ៥,៩៦% | ៦,៨៤% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៤,៥% | ១៤,៤៩% | ១៧,៣៤% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤២% | ៤,៤២% | ៤,៤៣% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៦០% | ១១,៧៩% | ១១,៨២% |
| អត្រាការប្រាក់កម្ចីជារៀលនៅហត្ថាកសិករ | ១៨% | ១៨% | ៣១,២% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | ១៨% | ១៨% | ២៨,៨% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | ១៦,៣% | ១៧,៨% | ២២,៨% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងថាមពល

➡ក្នុងខែតុលា ឆ្នាំ២០១៧ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៩៥,៣៩ពាន់តោន កើនឡើង១២% ធៀបនឹងខែមុន និងកើនឡើង១៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

## ➢រ៉ែ និងថាមពល:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៦៩៧GWHមានការកើនឡើង៣,៦%ធៀបនឹងខែមុន និងកើនឡើង៣៤%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ៣៨៩,១៣GWH មានការថយចុះ៧% ធៀបនឹងខែមុន និងថយចុះ១៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន២៦៦,៥៦GWHមានការកើនឡើង១២%ធៀបនឹងខែមុន និងមានការកើនឡើង៣៦៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

## ➢ឧស្សាហកម្ម:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៧១៤,៩លានដុល្លារ មានការកើនឡើង១០% ធៀបនឹងខែមុន និងកើនឡើង២,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន –តុលា២០១៧ | ចំនួន–កញ្ញា២០១៧ | ចំនួន–តុលា២០១៦ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៤ | ៣៩ | ៦ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៦៩៦ | ១៦៩២ | ១៥៦០ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ២២ | ២០ | ១៤ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១៨ | ៤២ | ២៤ |

## ➢សំណង់ (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ១២១៧,៩ពាន់ម²កើនឡើង៣២៨%ធៀបនឹងខែមុន និងកើនឡើង ៥៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង៦៣១,៦លានដុល្លារ កើនឡើង៣១១%ធៀបនឹងខែមុន និងកើនឡើង១០៩%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម² –តុលា២០១៧ | ពាន់ម² –កញ្ញា២០១៧ | ពាន់ម² –តុលា២០១៦ |
|---|---|---|---|
| ▪ លំនៅឋាន | ៤៨៣,២ | ១១១,១ | ៣០០,៩ |
| ▪ ឧស្សាហកម្ម | ១៧០,៦ | ៤៤,៧ | ៤១៦,៦ |
| ▪ពាណិជ្ជកម្ម | ៥២៧,៨ | ១១៨,៣ | ៦១ |
| ▪ ទេសចរណ៍ | ៣៥,៨ | ៩,២ | ០ |
| ▪ផ្សេងៗ | ០,៥ | ០,៩ | ០ |
| អនុញ្ញាតសរុប | ១២១៧,៩ | ២៨៤,៣ | ៧៧៨,៥ |

✓ដូច្នេះ សំណង់អនុញ្ញាតដែលពេញនិយមនាខែនេះ គឺ ពាណិជ្ជកម្ម៤៣,៣៣% និង លំនៅដ្ឋាន៣៩,៦៨% នៃផ្ទៃក្រឡាសរុប។

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់–តុលា ២០១៧ | នាក់–កញ្ញា ២០១៧ | នាក់–តុលា ២០១៦ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ១២៨៨ | ៩១០ | ៨៩០ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៩៤២៩ | ១៦៦៥៧ | ៤១៩៧ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៥០១២ | ១២២៦៤ | ២៧៥៤ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៤៤១៧ | ៤៣៩៣ | ១៤៤៣ |

## ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | តុលា២០១៧ | កញ្ញា២០១៧ | តុលា២០១៦ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ១២៦,១ | ៣៦,៥ | ២៥,២ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០ | ០ | ០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ១២៦,១ (៧២,៤) | ៣៦,៥ (១២,៧) | ២៥,២ (២) |
| វិស័យទេសចរណ៍ | ០ | ០ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ០ | ០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ២០ | ១០ | ៧ |
| បង្កើតការងារ (ពាន់នាក់) | ១០ | ៧,៣ | ៤,៣ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន ៧៨៤ពាន់តោន ថយចុះ៧% ធៀបនឹងខែមុន និងកើនឡើង៤៨%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ:

តារាង៤.៥.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:-៣% | (+២៤%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:+១៧% | (+៥១%) |
| ▪ កំពង់ផែកំពង់សោម:-៥% | (+៨៦%) | ▪ កំពង់ផែឧកញ៉ាម៉ុង: -៩១% | (-៤៥%) |

### ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១៦,៥ | ១៥% | ១១% |
| ក្នុងនោះទទួល | ២,៥ | ២៧% | ១២% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៩១,៨ | ៣២% | ៥% |
| ក្នុងនោះទទួល | ៥៦ | ៣៥% | ១៧% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២០២២,៤ | ៣% | -២២% |
| ក្នុងនោះហៅចូល | ៦០៩,៨ | ៣% | -២២% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៥៩១៣,៧ | -២៥% | -២៩% |
| ក្នុងនោះហៅចូល | ៥៨៥០ | -២៥% | -២៩% |

## ➢ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១៦,៦ | ៥៧% | ៣៨% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៤៦,៥ | ១៩% | ៤៥% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៦១៩,៤ | ១១% | ២៤% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១៤៦,៨ | -១១,៨% | ១៩% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៤១៧ | ១១% | ១% |
| ✓ តាមផ្លូវអាកាស | ២៦៩,២ | ១៦% | ២០% |
| ✓ តាមផ្លូវគោក និងទឹក | ១៤៧,៩ | ៣% | -២២% |

## ៥) ស្ថានភាពពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនា ខែតុលា ឆ្នាំ២០១៧ មានចំនួន៤៦០៣,៩ប៊ីលានរៀល (ស្មើនឹង១១៥០,៩លានដុល្លារ ស.រ.អា.) កើនឡើង១,៨% ធៀបនឹងខែមុន និងកើនឡើង៨,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ:

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +៦,៤% | +៣៨,៤% | រថយន្តសរុប (ប៊ី.ឈ.រ) | +៦% | +៤៨,២% |
| ប្រេងម៉ាស៊ូត | -៧% | +៩% | រថយន្តសរុប (គ្រឿង) | +១៩,៨% | +៣៧,៣% |
| ឧស្ម័ន | +២,៦% | +៣១,២% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +៧៥,១% | +៦៦,៤% |
| អគ្គិសនីនាំចូល | +៤៨% | +៥៥% | ម៉ូតូ (គ្រឿង) | +២០,៥% | -៨,២% |
| ដែកសំណង់ | +១២% | +៥៤% | អង្ករ | -៦៩,៤% | -៥៧,៦% |
| ស៊ីម៉ង់ត៍ | -២២,៧% | +២% | ផ្លែឈើនិងបន្លែ | -២១,២% | -៤៤,៣% |
| គ្រឿងអេឡិចត្រូនិក | +១៩,៩% | +៣៩,០% | ជីនិងថ្នាំកសិកម្ម | +៤១,៦% | -៦៤,៤% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៣០,៦% | +៧,១% |

➡ **ការនាំចេញ** ខែតុលា ឆ្នាំ២០១៧ មានចំនួន**៣៦៨៥,៣**ប៊ីលានរៀល ស្មើនឹង៩២១,៣លានដុល្លារស.រ.អា(៨០% នៃការនាំចូល)ថយចុះ១៧,១%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៣២,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| *ទំនិញ* | *%ធៀបនឹងខែមុន* | *%ធៀបនឹងខែដូចគ្នាឆ្នាំមុន* | *ទំនិញ* | *%ធៀបនឹងខែមុន* | *%ធៀបនឹងខែដូចគ្នាឆ្នាំមុន* |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +៦,២% | +៤៦៧,៩% | ផលិតផលនេសាទ | -៣,១% | +៩៤,២% |
| វាយនភណ្ឌនិងស្បែកជើង | -១៤,២% | +៣២,២% | កៅស៊ូ | -១០,៦% | +២៣,៥% |
| អង្ករ | +៤,២% | -១២,១% | | | |

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែតុលា ឆ្នាំ២០១៧នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែមប្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃប្រេងសាំង | +០,១% | +៧,៦% | |
| ២ | ថ្លៃប្រេងម៉ាស៊ូត | +០,៣% | +៧,២% | |
| ៣ | ការនាំចូលអង្ករ | -៦៩,៤% | -៥៧,៦% | |
| ៤ | ការនាំចូលផ្លែឈើ និងបន្លែ | -២១,២% | -៤៤,៣% | |



### ៧) សេចក្តីសន្និដ្ឋាន®

១) ជារួម អត្រាអតិផរណារំពឹងថានឹងមានកម្រិតទាប ជុំវិញ ៣% ក្នុងឆ្នាំ ២០១៧ នេះ ប៉ុន្តែមុខទំនិញមួយចំនួន ដូចជា ប្រេងឥន្ធនៈ និងត្រី នៅមានកំណើនខ្ពស់។

២) ការយកចិត្តទុកដាក់លើបញ្ហាសង្គមរបស់រាជរដ្ឋាភិបាល ចំពោះកម្មករកាត់ដេររួមមាន៖

ក. តម្លើងប្រាក់ឈ្នួលអប្បបរមា ១៧០ដុល្លាជូនកម្មករចាប់ពីខែមករា ឆ្នាំ២០១៨។

ខ. អនុញ្ញាតឲ្យកម្មករ និយោជិត មកពីគ្រប់វិស័យជិះរថយន្តក្រុងរបស់សាលារាជធានីភ្នំពេញ ដោយឥតគិតថ្លៃរយៈពេល២ឆ្នាំ ចាប់ពីថ្ងៃទី២០ ខែសីហា ២០១៧ ដល់ ២០ សីហា ២០១៩។

គ. ចាប់ពីខែមករា ឆ្នាំ២០១៨ ថៅកែរោងចក្រ សហគ្រាស ត្រូវទទួលរ៉ាប់រងរាល់សេវាគាំពារសុខភាពរបស់កម្មករ និយោជិត។

ឃ. ចាប់ពីឆ្នាំ២០១៩ កម្មករ និយោជិត មានប្រាក់សោធននិវត្តន៍ដូចមន្ត្រីរាជការ។ប្រាក់នេះសម្រាប់ជួយដោះស្រាយ ជីវភាពកម្មករ និយោជិត នៅពេលពួកគេចាស់បម្រើការងារលែងកើត។

ង. កម្មករ និយោជិត មកពីគ្រប់វិស័យទាំងអស់អាចចូលពិនិត្យ និងព្យាបាលជំងឺក្នុងមន្ទីរពេទ្យរដ្ឋដោយឥតគិតថ្លៃ។

ច. ចាប់ពីឆ្នាំ២០១៨តទៅ រាជរដ្ឋាភិបាល ក៏នឹងឧបត្ថម្ភដល់កម្មការិនីនៅពេលពួកគេសម្រាលកូនផងដែរ។ ក្នុងនោះអ្នកសម្រាលកូន១ ទទួលបានប្រាក់ឧបត្ថម្ភ ៤០ម៉ឺនរៀល សម្រាលកូនភ្លោះ២ ទទួលបានប្រាក់ឧបត្ថម្ភ ៨០ម៉ឺនរៀលហើយអ្នកសម្រាលបានកូនភ្លោះ៣ ទទួលបានប្រាក់ឧបត្ថម្ភ ១លាន ២០ម៉ឺនរៀល។

ឆ. កម្មការិនីមានផ្ទៃពោះ ត្រូវបានសម្រេចឲ្យចេញមុនម៉ោងធ្វើការយ៉ាងតិច ១៥នាទី ហើយនៅពេលសម្រាលត្រូវបាន អនុញ្ញាតឲ្យឈប់សម្រាករយៈពេលបីខែ ជាមួយអត្រាប្រាក់ខែ ១២០ភាគរយ។

កញ្ចប់អត្ថប្រយោជន៍នេះពិតជាជួយសម្រួលយ៉ាងច្រើនទាំងជីវភាព ផ្លូវចិត្ត និងសុខមាលភាពពួកគាត់។

៣) សីលធម៌ល្អ ការរស់នៅស្អាត មានអនាម័យ ព្រមទាំងសណ្តាប់ធ្នាប់ល្អ របស់ប្រជាជន ជាកិច្ចការដ៏មានសារសំខាន់ក្នុងសង្គមជាតិក្នុងដំណើរការអភិវឌ្ឍ។ បច្ចុប្បន្ន ការខ្វះខាតវប្បធម៌រស់នៅល្អ នៅជាបញ្ហាចម្បងមួយក្នុងសង្គមកម្ពុជានៅឡើយ ទាំងក្នុងផ្ទះ ទីសាធារណៈ កន្លែងធ្វើការ មន្ទីរពេទ្យ ជាដើម ទោះមានចលនាសាធារណៈបានបំផុសឡើង ដូចជា ការផ្សព្វផ្សាយពាក្យស្លោក "រមណីយដ្ឋានស្អាត អនាម័យល្អ" "ទាំងអស់គ្នាដើម្បីបរិស្ថាន" "តោះនាំគ្នាសម្អាតផ្ទះរបស់យើង" "សម្រាមមិនធ្លាក់ដល់ដី" ជាដើម ដើម្បីជះឥទ្ធិពលលើគំនិតនិងទម្លាប់របស់ប្រជាពលរដ្ឋក៏ដោយ។ អង្គប្រជុំបានលើកឡើងថា ការបណ្តុះស្មារតី សីលធម៌ល្អនិងការរស់នៅស្អាត ត្រូវធ្វើទាំងក្នុងសាលា ក្រៅសាលា និងការចូលរួមទាំងអស់គ្នាដើម្បីកែទម្លាប់៕

[®] ជាទូទៅ ផ្នែកនេះរំលេចតែបញ្ហាចម្បងៗនៃស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ប៉ុណ្ណោះ។

## III- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០២/១១/១៧ ម៉ោង១៥:០០នាទី | ចូលរួមជាកិត្តិយស ក្នុងព្រះរាជពិធីបុណ្យប្រពៃណីជាតិ អុំទូក បណ្តែតប្រទីប ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅមុខព្រះបរមរាជវាំង។ |
| ២ | ០៤/១១/១៧ ម៉ោង១៥:០០នាទី | ចូលរួមជាកិត្តិយស ក្នុងព្រះរាជពិធីបុណ្យប្រពៃណីជាតិ អុំទូក បណ្តែតប្រទីប ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅមុខព្រះបរមរាជវាំង។ |
| ៣ | ០៥/១១/១៧ ម៉ោង០៨:០០នាទី | ចូលរួមកិច្ចប្រជុំស្តីពីសភាពការណ៍នយោបាយថ្មីៗនៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ជិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ៤ | ០៦/១១/១៧ ម៉ោង០៩:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយផ្នែកគណនេយ្យ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៨/១១/១៧ ម៉ោង១៤:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីខួបអនុស្សាវរីយ៍លើកទី៦៤ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា និងទិវាកំណើត នៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ជិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅវិមានឯករាជ្យ និងស្ទូបព្រះបរមរូប “ព្រះករុណាព្រះបរមរតនកោដ្ឋ”។ |
| ៦ | ០៩/១១/១៧ ម៉ោង០៧:២០នាទី | ចូលរួមជាកិត្តិយស ក្នុងព្រះរាជពិធីប្រទានភ្លើងជ័យ បុណ្យខួបអនុស្សាវរីយ៍ លើកទី ៦៤ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានឯករាជ្យ។ |
| ៧ | ១០/១១/១៧ ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៨ | **១១/១១/១៧ ម៉ោង០៨:០០នាទី** | ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផល នៃការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៧ ការប្តូរការិយាល័យបោះឆ្នោត និងការធ្វើសៀវភៅគ្រួសារបក្សនៅទូទាំងខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៉ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ៩ | **១១/១១/១៧ ម៉ោង១៦:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងព្រះរាជពិធីពន្លត់ភ្លើងជ័យ បុណ្យខួបអនុស្សាវរីយ៍លើកទី ៦៤ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានឯករាជ្យ។ |
| ១០ | **១៥/១១/១៧ ម៉ោង០៩:៣០នាទី** | ជួបពិភាក្សាការងារជាមួយលោក **លី ស្មើ** នៅបន្ទប់ឯកឧត្តមប្រធាន(ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | **១៦/១១/១៧ ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិតនៅតំបន់ 7NG ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ |
| ១២ | **១៦/១១/១៧ ម៉ោង១៨:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីរាត្រីសមោសរប្រចាំឆ្នាំដែលរៀបចំដោយ សភា-ពាណិជ្ជកម្ម និងឧស្សាហកម្មបារាំង-កម្ពុជា នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។ |
| ១៣ | **២០/១១/១៧ ម៉ោង០៨:០០នាទី** | ជួបប្រជុំការងារជាមួយលោក **Eric DELOBEL CEO** ក្រុមហ៊ុន SCA នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | **២០/១១/១៧ ម៉ោង១១:០០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ផែន សុវិជ្ជានោ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | **២៥/១១/១៧ ម៉ោង០៨:០០នាទី** | ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសភាពការណ៍ថ្មីបន្ត និងវឌ្ឍនភាពនៃការធ្វើសៀវភៅគ្រួសារបក្ស ដើម្បីធ្វើបច្ចុប្បន្នភាពចំនួនសមាជិកបក្សគ្រប់ស្រុក ក្រុងទូទាំងខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៉ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៦ | **២៧/១១/១៧ ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយតំណាងអាចារ្យ-អាចារិនី មកពីទូទាំងប្រទេស ក្រោមអធិបតីភាព លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១៧ | **៣០/១១/១៧ ម៉ោង០៨:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំខែតុលា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៨ | **៣០/១១/១៧ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែតុលា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in